# សេចក្តីសង្ខេបប្រតិបត្តិ

# ស្តីពីក្របខណ្ឌគោលផែនការជនជាតិដើមភាគតិច

## គោលបំណងនៃក្របខណ្ឌគោលផែនការជនជាតិដើមភាគតិច

ក្របខណ្ឌគោលផែនការជនជាតិដើមភាគតិច (IPPF) មានគោលបំណងកំណត់នូវលក្ខខណ្ឌតម្រូវស្តង់ដារបរិស្ថាន និងសង្គមផ្នែកទី 7 របស់ធនាគារពិភពលោក (ESS7) របស់ធនាគារពិភពលោកស្តីពីជនជាតិដើមភាគតិច/សហគមន៍មូលដ្ឋានប្រពៃណីដែលជួបការលំបាកជាប្រវត្តិសាស្ត្រ នៅអាហ្វ្រិកក្នុងអនុតំបន់សាហារ៉ា និងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិចរបស់រាជរដ្ឋាភិបាល។ ដោយផ្អែកលើគម្លាតខ្វះខាតរវាងគោលនយោបាយរបស់ធនាគារពិភពលោក និងគោលនយោបាយរបស់រាជរដ្ឋាភិបាល វិធានការមួយចំនួនត្រូវបានស្នើឡើងដើម្បីបំពេញចំណុចខ្វះខាតទាំងនេះតាមរយៈការរៀបចំការអនុវត្តកិច្ចសន្យា នីតិវិធី លក្ខណៈវិនិច្ឆ័យនៃការរៀបចំ។ល។ ដើម្បីអនុវត្តចំពោះសមាសធាតុអនុគម្រោង និងសមាសធាតុគម្រោងទាំងអស់ ដែលត្រូវបានបញ្ជាក់នៅក្នុងអំឡុងពេលនៃការរៀបចំគម្រោង ហើយនឹងត្រូវកំណត់នៅក្នុងអំឡុងពេលអនុវត្តគម្រោង ដូចជា SC 1.4 នៃសមាសធាតុទី 1 និងសមាសធាតុទី 2។

ក្របខណ្ឌគោលផែនការជនជាតិដើមភាគតិច (IPPF) នេះលើកឡើងអំពីនីតិវិធីសម្រាប់ការត្រួតពិនិត្យការវាយតម្លៃ និងការរៀបចំបង្កើតផែនការសម្រាប់ជនជាតិដើមភាគតិច (IPP) ជាក់លាក់តាមទីតាំងសម្រាប់អនុគម្រោង ដែលត្រូវបញ្ជាក់នៅក្នុងអំឡុងពេលអនុវត្តគម្រោង។ ជាការសំខាន់ដែលត្រូវសង្កត់ធ្ងន់ថា ក្នុងករណីដែលត្រូវការផែនការសម្រាប់ជនជាតិដើមភាគតិច (IPP) (ដោយផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ IP) សកម្មភាពគម្រោង ជាពិសេស គម្រោងសាងសង់រូបវន្ត នឹងមិនអាចចាប់ផ្តើមបាននោះទេរហូតទាល់តែផែនការសម្រាប់ជនជាតិដើមភាគតិច (IPP) នីមួយៗ ត្រូវបានរៀបចំបង្កើតឡើង ពិនិត្យបញ្ចប់ស្ថាពរ និងអនុវត្តបានយ៉ាងពេញលេញដោយផ្អែកលើការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយជនជាតិដើមភាគតិចដែលអាចទទួលរងផលប៉ះពាល់ដែលមានវត្តមាននៅក្នុងតំបន់អនុគម្រោង។ គួរកត់សម្គាល់ផងដែរថា គម្រោងនេះ ចាំបាច់ត្រូវរៀបចំស្នើសុំការយល់ព្រមដោយសេរី ជាមុន និងផ្តល់ព័ត៌មានគ្រប់គ្រាន់ (FPIC) ពីសហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ ប្រសិនបើគម្រោងនោះ៖

ក្របខណ្ឌគោលផែនការជនជាតិដើមភាគតិច (IPPF) មានយន្តការដោះស្រាយបណ្តឹងតវ៉ា (GRM) ដែលអាចឱ្យជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ដាក់ពាក្យបណ្តឹងដើម្បីស្វែងរកដំណោះស្រាយពីគម្រោងបាន។ ក្របខណ្ឌគោលផែនការជនជាតិដើមភាគតិច (IPPF) នេះក៏បានរៀបចំបង្កើតការ

ព្រមព្រៀងដែលត្រូវបានធ្វើឡើងដោយក្រសួងរ៉ែ និងថាមពល (MME) អគ្គិសនីកម្ពុជា (EDC) និងតួអង្គពាក់ព័ន្ធនៅថ្នាក់ជាតិ និងមូលដ្ឋាន ដូចជា ថ្នាក់ខេត្ត ស្រុក និងឃុំ ដើម្បីធានាថា បទដ្ឋាន លក្ខខណ្ឌតម្រូវ និងវិធីសាស្ត្រពាក់ព័ន្ធ។ល។ ដែលមានចែងនៅក្នុងក្របខណ្ឌគោលផែនការជនជាតិដើមភាគតិចនេះ ត្រូវបានអនុវត្តយ៉ាងសមស្រប។ ក្របខណ្ឌគោលផែនការជនជាតិដើមភាគតិច (IPPF) មានផ្តល់ជូននូវការប៉ាន់ប្រមាណថ្លៃចំណាយសម្រាប់សកម្មភាពនានាពាក់ព័ន្ធដែលអាចកើតឡើងនៅក្នុងអំឡុងពេលអនុវត្តគម្រោង រួមទាំង ប្រភពមូលនិធិដែលត្រូវបានរៀបចំឡើង ដើម្បីធានាឱ្យបាននូវអត្ថិភាពមូលនិធិធានាសម្រាប់អនុវត្តសកម្មភាពដែលមានលើកឡើងនៅក្នុងក្របខណ្ឌគោលផែនការជនជាតិដើមភាគតិច (IPPF)។

## ហានិភ័យ និងផលប៉ះពាល់លើបរិស្ថាន និងសង្គម

នៅក្នុងអំឡុងពេលសាងសង់ ហានិភ័យបរិស្ថានដែលពាក់ព័ន្ធចម្បងទៅនឹងកម្លាំងពលកម្ម រួមទាំងហានិភ័យពាក់ព័ន្ធនឹងសុខភាព និងសុវត្ថិភាពការងាររបស់កម្មករនិយោជិតរបស់អ្នកទទួលរងគ្រោះថ្នាក់រូបរាងកាយ គ្រោះថ្នាក់គីមី និងហានិភ័យដែលពាក់ព័ន្ធនឹងបញ្ហាកង្វះ ឬការប្រើប្រាស់ មិនត្រឹមត្រូវនូវឧបករណ៍ការពារផ្ទាល់ខ្លួន (PPE)។ SC1.5 នៅក្រោមសមាសធាតុគម្រោងទី 1 ត្រូវបានរំពឹងថានឹងបង្កផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាននៅក្នុងតំបន់មូលដ្ឋាន ជាពិសេស នៅការដ្ឋានសំណង់ រួមមានដូចជា សំឡេងរំខាន និងរំញ័របណ្តោះអាសន្ននៅក្នុងតំបន់ដែលនៅជាប់នឹងតំបន់ការពារបរិស្ថាន ការបំពុលខ្យល់ ទឹក និងដី និងកាកសំណល់ ។ល។ ដែលកើតឡើងដោយសារតែសកម្មភាពសាងសង់។ ផលប៉ះពាល់ទាំងនេះអាចនឹងបង្កការរំខានដល់ជីវៈចម្រុះ និងប្រជាជនដែលកំពុងរស់នៅ ឬធ្វើសកម្មភាពរកប្រាក់ចំណូលនៅក្បែរការដ្ឋានសំណង់។ លើសពីនេះ ក្នុងអំឡុងពេលអនុវត្តសកម្មភាពសាងសង់ ផលប៉ះពាល់បរិស្ថានអវិជ្ជមានផ្សេងទៀតដែលអាចកើតឡើង អាចរួមមាន៖ (i) ការសឹករេចរឹល និងការហូរច្រោះដែលអាចកើតមានទៅកាន់ផ្លូវទឹកនៅក្បែរនោះ ជាពិសេសនៅក្នុងអំឡុងពេលអនុវត្តប្រតិបត្តិការការងារឈូសឆាយដី (earthworks) (ii) ការបំពុលទឹកដោយសារប្រមូលផ្តុំសារធាតុផ្សំ/សម្ភារសំណង់ ដូចជា ដី ក្រួស (iii) ការបំពុលដែលបង្កឡើងដោយសារសំឡេងរំខាន ទឹកកខ្វក់ សំណល់រឹង ប្រេងម៉ាស៊ីនប្រើរួចដែលបង្ហូរចេញពីរោងជាងកម្មករ។ ផលប៉ះពាល់បរិស្ថានទាំងនេះភាគច្រើនគឺទំនងជាមានជាបណ្តោះអាសន្ន ហេតុដូច្នេះ អាចកែប្រែឱ្យមានស្ថានភាពដើមវិញ និងអាចគ្រប់គ្រងបាន តាមរយៈការអនុវត្តការសាងសង់ល្អ និងផែនការគ្រប់គ្រងបរិស្ថាន និងសង្គម។ ផលប៉ះពាល់បរិស្ថានសរុបរួមត្រូវបានរំពឹងទុកថាមាន ប៉ុន្តែត្រូវបានវាយតម្លៃថាមានវិសាលភាពតិចតួច និងមានកម្រិតស្រាល ដោយសារតែលក្ខណៈនៃការងារសាងសង់នេះ

មានទំហំតូច និងរយៈពេលខ្លី។ ការត្រួតពិនិត្យរកផលប៉ះពាល់ដែលអាចមាន នឹងត្រូវធ្វើឡើងនៅក្នុងអំឡុងពេលធ្វើការត្រួតពិនិត្យផ្នែកបរិស្ថាន និងសង្គម ដែលនឹងត្រូវអនុវត្តសម្រាប់អនុគម្រោងនីមួយៗដែលបានកំណត់។

ហានិភ័យសង្គមដែលអាចកើតមានចំពោះប្រជាជននៅក្នុងតំបន់មូលដ្ឋាន រួមទាំងជនជាតិដើមភាគតិចដែលអាចនឹងមានវត្តមាននៅក្នុងតំបន់អនុគម្រោង គឺមានពាក់ព័ន្ធនឹងលំហូរចូលនៃកម្លាំងពលកម្ម ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ/ការបៀតបៀនផ្លូវភេទ (SEA/SH) ពលកម្មកុមារ កម្លាំងពលកម្មដោយបង្ខំ ការរើសអើង និងការមិនរាប់បញ្ចូលក្រុមជួបការលំបាក/ក្រុមងាយរងគ្រោះ និងកម្មករនិយោជិតបណ្ដោះអាសន្ន។ ផលប៉ះពាល់សំខាន់ៗដែលពាក់ព័ន្ធនឹងការធ្វើលទ្ធកម្មដីធ្លី/ការបាត់បង់ទ្រព្យសម្បត្តិ និងជីវភាពរស់នៅភាគច្រើនគឺបណ្ដាលមកពីសកម្មភាពសាងសង់នៃអនុសមាសធាតុ 1.5 ក្រោមសមាសធាតុទី 1។ សកម្មភាពក្រោមអនុសមាសធាតុផ្សេងទៀត និងសមាសធាតុទី 2 គឺមិនពាក់ព័ន្ធនឹងការធ្វើលទ្ធកម្មដីធ្លី ឬបង្កឱ្យមានផលប៉ះពាល់លើទ្រព្យសម្បត្តិ និងជីវភាពរស់នៅរបស់ប្រជាជននោះទេ។ ផលប៉ះពាល់អវិជ្ជមានដែលអាចមានពីសកម្មភាពសាងសង់នៃអនុសមាសធាតុ 1.5 អាចរួមមាន ការបាត់បង់ដីធ្លី ការបាត់បង់ទ្រព្យសម្បត្តិដែលមានជាប់នៅលើដី ការបាត់បង់ដើមឈើមានតម្លៃ និងការបាត់បង់មធ្យោបាយប្រកបរបរចិញ្ចឹមជីវិតជាដើម ជាពិសេស សម្រាប់ចំពោះជនដែលដីរបស់ពួកគេទទួលរងផលប៉ះពាល់/ត្រូវបានធ្វើលទ្ធកម្មសម្រាប់សាងសង់បណ្ដាញចែកចាយ MV និង LV តភ្ជាប់ទៅកាន់ភូមិដែលគ្មានអគ្គិសនីប្រើប្រាស់។ បង្គោល MV និង LV ធ្វើលទ្ធកម្មដីគឺមានទំហំត្រឹមតែ 5 ម៉ែត្រ x 5 ម៉ែត្រ និងបង្គោលភ្លើងគឺមានទំហំ 30 សង់ទីម៉ែត្រ x 30 សង់ទីម៉ែត្រ ដូច្នេះគឺមិនមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ដល់សកម្មភាពរស់នៅប្រចាំថ្ងៃនោះទេ។ ទោះជាយ៉ាងណាក៏ដោយ មានលទ្ធភាពអាចកើតឡើងដែលខ្សែ MV និង LV អាចនឹងរត់ឆ្លងកាត់តំបន់មួយដែលមានភូមិជនជាតិដើមភាគតិច រួមទាំង តំបន់ព្រៃអារក្ស ដីព្រៃកប់សព ឬតំបន់ប្រើប្រាស់ជាប្រពៃណីរបស់ពួកគេ ដែលអាចមានផលប៉ះពាល់ផ្នែកវប្បធម៌ដ៏គួរឱ្យកត់សម្គាល់។ ជនជាតិដើមភាគតិចមានទំនាក់ទំនងខាងព្រលឹងវិញ្ញាណយ៉ាងជ្រាលជ្រៅទៅនឹងដីធ្លីរបស់ពួកគេ ការយក ឬការបំផ្លិចបំផ្លាញតំបន់ទាំងនេះ អាចបណ្ដាលមិនត្រឹមតែឱ្យមានការបាត់បង់ជាលក្ខណៈរូបវន្ត (ធនធានព្រៃឈើ ។ល។) ប៉ុណ្ណោះទេ ប៉ុន្តែក៏បង្កឱ្យមានភាពតានតឹងផ្នែកវប្បធម៌ និងផ្លូវចិត្តផងដែរ។ ក៏អាចមានហានិភ័យនៃការពិគ្រោះយោបល់មិនគ្រប់គ្រាន់ដែរ ប្រសិនបើគម្រោងមិនបានកៀរគរឱ្យមានការចូលរួមពីសំណាក់សហគមន៍ជនជាតិដើមភាគតិច ឱ្យបានត្រឹមត្រូវដោយប្រើភាសារបស់ពួកគេ និងដោយការគោរពចំពោះដំណើរការនៃការធ្វើការសម្រេចចិត្តរបស់ពួកគេទេ នោះអាចនឹងមានការយល់ខុស ឬការប្រឆាំងតវ៉ា។ ទិដ្ឋភាពមួយទៀតនោះគឺបេតិកភណ្ឌវប្បធម៌អរូបី រួមមាន ភាសា និងការអនុវត្តរបស់ជនជាតិដើមភាគតិច។ ប្រសិនបើមានកម្មករពីខាងក្រៅចូល

មកក្នុងតំបន់របស់ជនជាតិដើមភាគតិច (សម្រាប់ការងារសាងសង់) ដោយមិនបានគិតគូរទៅលើភាពរសើបផ្នែកវប្បធម៌ទេ នោះអាចមានទំនាស់ផ្នែកសង្គម ឬការប៉ះពាល់ដល់ទំនៀមទម្លាប់ក្នុងមូលដ្ឋានរបស់ពួកគេ។ ទោះបីជាយ៉ាងណាក៏ដោយ ចំណែកឯផ្នែកវិជ្ជមានវិញ ការតភ្ជាប់បណ្តាញអគ្គិសនីនៅក្នុងភូមិជនជាតិដើមភាគតិច ត្រូវបានរំពឹងថានឹងទទួលបានការគាំទ្រយ៉ាងខ្លាំងប្រសិនបើធ្វើឡើងដោយមានការគោរព (សហគមន៍ជនជាតិដើមភាគតិចជាច្រើនមានបំណងចង់បានការអភិវឌ្ឍ ប៉ុន្តែចង់ក្លាយជាដៃគូចូលរួមនៅក្នុងដំណើរការនេះ)។ រាល់ការងារទាំងឡាយណាដែលអាចបង្កផលប៉ះពាល់អវិជ្ជមានដល់សុចរិតភាព ឬផលិតភាពនៃដីធ្លីសហគម្មសិទ្ធិរបស់ជនជាតិដើមភាគតិច នឹងត្រូវធ្វើការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន ហើយនឹងត្រូវដកចេញវិញ។ ការងារនានាអាចអនុវត្តនៅជាប់នឹងដីធ្លីសហគម្មសិទ្ធិរបស់ជនជាតិដើមភាគតិច ប៉ុន្តែមិនត្រូវបង្កផលប៉ះពាល់ដល់សុចរិតភាព ឬផលិតភាពរបស់ដីធ្លីទាំងនោះឡើយ។ ដូច្នេះ ការយល់ព្រមដោយសេរី ជាមុន និងផ្តល់ព័ត៌មានគ្រប់គ្រាន់ (FPIC) នឹងមិនអាចអនុវត្តចំពោះគម្រោងនេះឡើយ។

## វិធានការកាត់បន្ថយហានិភ័យ

ទោះបីជាហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គមដែលបានរៀបរាប់ខាងលើនឹងត្រូវធ្វើការផ្ទៀងផ្ទាត់ និងវាយតម្លៃឡើងវិញនៅពេលដែលទីតាំងអនុគម្រោងបានស្គាល់ច្បាស់ក៏ដោយ ជនជាតិដើមភាគតិចដែលនៅក្នុងតំបន់អនុគម្រោងអាចទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ បើធៀបទៅនឹងក្រុមប្រជាជនទូទៅ។ លក្ខណៈចរិតផ្នែកវប្បធម៌ និងសង្គមសេដ្ឋកិច្ចពិសេសខុសប្លែករបស់ជនជាតិដើមភាគតិច រួមទាំង ជីវភាពរស់នៅដែលមានស្រាប់របស់ពួកគេ ជាដើម អាចធ្វើឱ្យជនជាតិដើមភាគតិចកាន់តែប្រឈមនឹងហានិភ័យ និងផលប៉ះពាល់បន្ថែមទៀត បង្កើនភាពងាយរងគ្រោះរបស់ពួកគេ និងធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេក្នុងការឆ្លើយតបទៅនឹងហានិភ័យ និងផលប៉ះពាល់ទាំងនោះ ប្រសិនបើពុំមានវិធីសាស្ត្រគ្រប់ជ្រុងជ្រោយសម្រាប់អនុវត្តទេនោះ។ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ដូចជា ព័ត៌មាន ការអប់រំផ្សព្វផ្សាយ និងការប្រាស្រ័យទាក់ទង (IEC) និងការចូលរួមយ៉ាងសកម្មរបស់ជនជាតិដើមភាគតិចដែលពាក់ព័ន្ធ គឺសុទ្ធសឹងតែជាកត្តាដ៏សំខាន់ៗដែលចូលរួមចំណែកធ្វើឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាព ពីសំណាក់ជនជាតិដើមភាគតិចដើម្បីអាចឱ្យមានការពិគ្រោះយោបល់មួយ ប្រកបដោយអត្ថន័យក្នុងអំឡុងពេលនៃការរៀបចំអនុគម្រោង និងការពិនិត្យតាមដានដោយមានការចូលរួមនៅក្នុងអំឡុងពេលអនុវត្តអនុគម្រោង។ ការសម្របសម្រួលរបស់តួអង្គពាក់ព័ន្ធគម្រោង រួមទាំងអង្គភាពគ្រប់គ្រងគម្រោង (PMU) អ្នកម៉ៅការសាងសង់ អាជ្ញាធរមូលដ្ឋាន ភ្នាក់ងារក្នុងមូលដ្ឋាន អ្នកផ្តល់សេវាក្នុងមូលដ្ឋាន ជាពិសេស ការចូល

រួមយ៉ាងសកម្ម និងពេញលេញរបស់ជនជាតិដើមភាគតិច ដែលរួមគ្នារួមចំណែកដល់ការកាត់បន្ថយហានិភ័យដែលបានកំណត់រកឃើញ និងផលប៉ះពាល់ដែលអាចកើតមាននៅទីតាំងអនុគម្រោងដែលបានកំណត់។

វិធានការកាត់បន្ថយលម្អិតសម្រាប់ហានិភ័យបរិស្ថាន និងសង្គមខាងលើ និងផលប៉ះពាល់ដែលអាចកើតមានត្រូវបានស្នើឡើងនៅក្នុងក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) នៃគម្រោង។ វិធានការសម្រាលហានិភ័យទាំងនេះ គឺមានលក្ខណៈជាក់លាក់សម្រាប់ដំណាក់កាលរចនាគម្រោង ដំណាក់កាលមុនការសាងសង់ និងដំណាក់កាលសាងសង់។

## ការរៀបចំផែនការជនជាតិដើមភាគតិច

ក្រសួងរ៉ែ និងថាមពល (MME) អគ្គិសនីកម្ពុជា (EDC) នឹងធ្វើការត្រួតពិនិត្យរកជនជាតិដើមភាគតិចសម្រាប់អនុគម្រោងនីមួយៗដែលត្រូវបានកំណត់នៅក្នុងអំឡុងពេលរៀបចំ និងអនុវត្តគម្រោង។ ប្រសិនបើមានវត្តមានជនជាតិដើមភាគតិចនៅក្នុងតំបន់អនុគម្រោង នោះក្រសួងរ៉ែ និងថាមពល (MME) អគ្គិសនីកម្ពុជា (EDC) នឹងធ្វើការវាយតម្លៃសង្គម (SA) គោលដៅដោយមានជំនួយបច្ចេកទេសពីទីប្រឹក្សាដែលមានសមត្ថភាពឯកទេសផ្នែកជនជាតិដើមភាគតិច។ ការវាយតម្លៃសង្គម (SA) នឹងធ្វើការត្រួតពិនិត្យ ដើម្បីស្វែងយល់ថាតើសកម្មភាពអនុគម្រោង នឹងបង្កើតឱ្យមានផលប៉ះពាល់អវិជ្ជមានដែលអាចមានណាមួយ ទៅលើទ្រព្យសម្បត្តិវប្បធម៌របស់ជនជាតិដើមភាគតិច ឬអត់ (រួមទាំងរូបី និងអរូបី)។ ការវាយតម្លៃសង្គម (SA) គោលដៅនឹងត្រូវធ្វើឡើងដោយផ្អែកលើការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ ដែលផ្អែកលើគោលការណ៍នៃការពិគ្រោះយោបល់ដោយសេរី ជាមុន និងផ្តល់ព័ត៌មានគ្រប់គ្រាន់ (FPIC)។ ព័ត៌មានគ្រប់គ្រាន់នឹងផ្តល់ជូនជនជាតិដើមភាគតិចដែលអាចរងផលប៉ះពាល់ ដើម្បីធានាឱ្យបាននូវការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ។ ព័ត៌មានលម្អិតអំពីវិសាលភាព មាត្រដ្ឋាន លក្ខណៈនៃសកម្មភាពអនុគម្រោង ទីតាំងអនុគម្រោង និងហានិភ័យ និងផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម ដែលបានកំណត់ពាក់ព័ន្ធនឹងសកម្មភាពសាងសង់ នឹងផ្តល់ជូនជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ ដើម្បីធានាឱ្យបាននូវការប្រមូលមតិត្រលប់ប្រកបដោយអត្ថន័យ។

ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃសង្គម (SA) គោលដៅ ផែនការជនជាតិដើមភាគតិច (IPP) នឹងត្រូវរៀបចំឡើង។ អគ្គិសនីកម្ពុជា (EDC) នឹងដាក់ផែនការជនជាតិដើមភាគតិច (IPP) ជូនធនាគារពិភពលោកពិនិត្យជាមុន មុននឹងចាប់ផ្តើមអនុវត្តសកម្មភាព។

## យន្តការដោះស្រាយបណ្ដឹងតវ៉ា

តាមរយៈកិច្ចប្រជុំពិគ្រោះយោបល់សាធារណៈនៅក្នុងតំបន់គម្រោង និងតាមរយៈកូនសៀវភៅព័ត៌មានគម្រោងដែលផ្តល់ជូនគ្រួសារដែលរងផលប៉ះពាល់ថា ក្រសួងរ៉ែ និងថាមពល (MME) និងអគ្គិសនីកម្ពុជា (EDC) នឹងធានាថាប្រជាជនដែលរងផលប៉ះពាល់ទាំងអស់បានយល់ដឹងយ៉ាងច្បាស់អំពីសិទ្ធិរបស់ពួកគេក្នុងការដាក់ពាក្យបណ្ដឹងតវ៉ា និងអំពីយន្តការដោះស្រាយបណ្ដឹងតវ៉ា។ ភាគីណាមួយដែលរងផលប៉ះពាល់ពីការធ្វើលទ្ធកម្មដីធ្លី ឬរងផលប៉ះពាល់ផ្សេងទៀតដែលពាក់ព័ន្ធនឹងការសាងសង់ និងប្រតិបត្តិការគម្រោង មានសិទ្ធិដាក់ពាក្យបណ្ដឹង។ គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ា (GRC) នឹងត្រូវបានបង្កើតឡើងនៅថ្នាក់ខេត្ត ជាមួយនឹងដំណើរការចាប់ផ្តើមពីកម្រិតរដ្ឋបាលឃុំ។ ដូចដែលធ្លាប់បានអនុវត្ត គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ា (GRC) រួមមានមេឃុំ ឬមេភូមិក្នុងមូលដ្ឋានដែលពាក់ព័ន្ធ ហើយក្នុងករណីចាំបាច់ អង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន អាចជួយដល់អ្នកដែលរងផលប៉ះពាល់ក្នុងការដាក់ពាក្យបណ្ដឹង។ មន្ត្រីឃុំដែលត្រូវបានចាត់តាំង ត្រូវខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីដោះស្រាយពាក្យបណ្ដឹង និងបញ្ហានៅថ្នាក់ឃុំ តាមរយៈការពិគ្រោះយោបល់ជាមួយសហគមន៍ដែលសមស្រប។ រាល់កិច្ចប្រជុំដោះស្រាយបណ្ដឹងតវ៉ាទាំងអស់ ត្រូវកត់ត្រាកំណត់ហេតុទុកជាឯកសារ ហើយសំណៅចម្លងកំណត់ហេតុនោះត្រូវផ្តល់ជូនដល់ជនដែលរងផលប៉ះពាល់។ សំណៅចម្លងនៃកំណត់ហេតុកិច្ចប្រជុំ និងវិធានការដែលបានអនុវត្ត ត្រូវផ្តល់ជូនក្រសួងរ៉ែ និងថាមពល (MME) និងអគ្គិសនីកម្ពុជា (EDC) និងធនាគារពិភពលោកនៅពេលមានការស្នើសុំ។ ការរាល់ចំណាយទាំងអស់លើការដោះស្រាយពាក្យបណ្ដឹង (កិច្ចប្រជុំ ការពិគ្រោះយោបល់ ការប្រាស្រ័យទាក់ទង និងការរៀបចំរបាយការណ៍/ការផ្សព្វផ្សាយព័ត៌មាន) គឺជាបន្ទុករបស់អគ្គិសនីកម្ពុជា។

យន្តការដោះស្រាយបណ្ដឹងតវ៉ា (GRM) មានជំហានចំនួនបួនសម្រាប់ដោះស្រាយទំនាស់ដូចខាងក្រោម៖ ជំហានទី 1 រាយការណ៍អំពីទំនាស់នោះជូនអ្នកម៉ៅការសាងសង់ ក្រុមប្រឹក្សាឃុំតាមរយៈមេភូមិ ឬមេឃុំ ជំហានទី 2 អាចបញ្ជូនទំនាស់នោះទៅកាន់ការិយាល័យគ្រប់គ្រងគម្រោង (PMO)/ការិយាល័យសង្គម បរិស្ថាន និងទំនាក់ទំនងសាធារណៈ (SEPRO) តាមរយៈក្រុមប្រឹក្សាឃុំ ជំហានទី 3 បញ្ជូនករណីទំនាស់នេះទៅកាន់រដ្ឋបាលស្រុក និងជំហានទី 4 បញ្ជូនបញ្ហាទាំងនោះទៅកាន់គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាថ្នាក់ខេត្ត (GRC)។

## ការរៀបចំការអនុវត្ត ការពិនិត្យតាមដាន និងការរាយការណ៍

ក្រសួងរ៉ែ និងថាមពល (MME) នឹងទទួលខុសត្រូវចំពោះសមាសធាតុគម្រោងទី 2 ស្តីពីប្រសិទ្ធភាពថាមពលក្នុងវិស័យឧស្សាហកម្ម ដែលត្រូវបានរៀបចំបង្កើតឡើងដើម្បីលើកកម្ពស់ការទទួលយកមកអនុវត្តបច្ចេកវិទ្យា និងការអនុវត្តប្រកបដោយប្រសិទ្ធភាពថាមពលនៅក្នុងវិស័យឧស្សាហកម្ម។ ក្រសួងរ៉ែ និងថាមពល ផ្តល់ឥណទានសម្បទានតាមរយៈអន្តរការីហិរញ្ញវត្ថុដល់សហគ្រាសឧស្សាហកម្មសម្រាប់ការទិញ ដំឡើង និងប្រតិបត្តិការឧបករណ៍មានប្រសិទ្ធភាពថាមពល (EE) ដែលអាចជួយកាត់បន្ថយបរិមាណនៃការប្រើប្រាស់ថាមពល និងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់។

អគ្គិសនីកម្ពុជា (EDC) នឹងទទួលខុសត្រូវអនុវត្តក្របខណ្ឌគោលផែនការជនជាតិដើមភាគតិច (IPPF) នេះ ដែលពាក់ព័ន្ធនឹងការរៀបចំបង្កើត ការសាងសង់ និងប្រតិបត្តិការ និងតំហែទាំ SC1.1, SC1.2, SC1.4 និង SC1.5 នៅក្រោមសមាសធាតុទី 1៖ ការពង្រឹងបណ្តាញអគ្គិសនីដើម្បីសម្រួលដល់ការធ្វើអន្តរកាលថាមពល និងការលក់ថាមពលអគ្គិសនីនៅក្នុងតំបន់។ អគ្គិសនីកម្ពុជា (EDC) នឹងប្រើការិយាល័យគ្រប់គ្រងគម្រោង (PMO) ហើយការិយាល័យនេះនឹងក្លាយជាស្ថាប័នអនុវត្តតាងនាមឱ្យអគ្គិសនីកម្ពុជា (EDC) សម្រាប់ការគ្រប់គ្រងគម្រោងប្រចាំថ្ងៃ ព្រមទាំងធានាថាក្របខណ្ឌគោលផែនការជនជាតិដើមភាគតិច (IPPF) នឹងត្រូវបានអនុវត្តតាមត្រឹមត្រូវ។ ការិយាល័យគ្រប់គ្រងគម្រោង (PMO) នឹងជ្រើសរើសទីប្រឹក្សាអនុវត្តគម្រោង (PIC) ដើម្បីជួយដល់ការិយាល័យគ្រប់គ្រងគម្រោង (PMO)/អគ្គិសនីកម្ពុជា (EDC) ក្នុងការអនុវត្តគម្រោង និងកាត្រួតពិនិត្យលើអ្នកទទួលការក្នុងអំឡុងពេលសាងសង់ ប្រតិបត្តិការ និងតំហែទាំ។ ទីប្រឹក្សាអនុវត្តគម្រោង (PIC) និងការិយាល័យសង្គម បរិស្ថាន និងទំនាក់ទំនងសាធារណៈ (SEPRO) នឹងធ្វើការរួមគ្នាដើម្បីធានាថាមានការត្រួតពិនិត្យត្រឹមត្រូវលើក្រុមជនជាតិដើមភាគតិច (IP) នឹងធ្វើឡើង សម្រាប់អនុគម្រោងនីមួយៗ និងជំហានសម្រាប់ការត្រួតពិនិត្យជនជាតិដើមភាគតិច (IP) និងការវាយតម្លៃសង្គមគោលដៅដែលមានបរិយាយនៅក្នុងក្របខណ្ឌគោលផែនការជនជាតិដើមភាគតិច (IPPF) នេះត្រូវបានអនុវត្តតាមត្រឹមត្រូវ។ ទីប្រឹក្សាអនុវត្តគម្រោង (PIC) និង ការិយាល័យសង្គម បរិស្ថាន និងទំនាក់ទំនងសាធារណៈ (SEPRO) នឹងទទួលខុសត្រូវអនុវត្តសកម្មភាពប្រចាំថ្ងៃដូចដែលបានកំណត់នៅក្នុងក្របខណ្ឌគោលផែនការជនជាតិដើមភាគតិច (IPPF) នេះ។ ទីប្រឹក្សាអនុវត្តគម្រោង (PIC) ក៏នឹងទទួលខុសត្រូវជួយការិយាល័យគ្រប់គ្រងគម្រោង(PMO) និងការិយាល័យសង្គម បរិស្ថាន និងទំនាក់ទំនងសាធារណៈ (SEPRO) និងអ្នកម៉ៅការសាងសង់ក្នុងការដោះស្រាយការតវ៉ា និង/ឬ បណ្តឹងសារទុក្ខដែលបានដាក់តាមរយៈយន្តការដោះស្រាយបណ្តឹងតវ៉ា (GRM) ប្រសិនបើមាន។

## ថ្លៃចំណាយ និងថវិកា

ថ្លៃចំណាយ និងថវិកាប៉ាន់ស្មានសម្រាប់ការអនុវត្តក្របខណ្ឌគោលផែនការជនជាតិដើមភាគតិច (IPPF) គឺជាចំនួនប៉ាន់ប្រមាណក្នុងអំឡុងពេលរៀបចំគម្រោងក្នុងគោលបំណងសម្រាប់ធ្វើផែនការថវិកា។ ការចំណាយជាក់ស្តែងនៃការអនុវត្តក្របខណ្ឌគោលផែនការជនជាតិដើមភាគតិច (IPPF) គឺអាស្រ័យទៅលើចំនួនផែនការសម្រាប់ជនជាតិដើមភាគតិច (IPP) រួមទាំង វិសាលភាព និងសកម្មភាពដែលត្រូវអនុវត្តនៅក្រោម IPP នីមួយៗក្នុងអំឡុងពេលអនុវត្តគម្រោង។ ថ្លៃចំណាយប៉ាន់ប្រមាណសរុបគឺមានចំនួន 161,040.00 ដុល្លារអាមេរិក។ ការចំណាយនេះអាចធ្វើបច្ចុប្បន្នភាពនៅពេលដែលបញ្ជីឈ្មោះអនុគម្រោងត្រូវបានបញ្ចប់ជាស្ថាពរ។ ថ្លៃចំណាយដែលកើតឡើងជាការទូទាត់សំណងសម្រាប់ការធ្វើលទ្ធកម្មដីធ្លី និងផលប៉ះពាល់ពាក់ព័ន្ធ ត្រូវរ៉ាប់រងដោយអគ្គិសនីកម្ពុជា (EDC) ហើយត្រូវបានប៉ាន់ប្រមាណនៅក្នុងក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ (RPF) របស់គម្រោង។